ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៩១/១៩ - អាកាសយានដ្ឋានអន្តរជាតិសៀមរាប

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល ម៉ារ សំបូរណា

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ ម៉ារ សំបូរណា

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អាកាសយានដ្ឋានអន្តរជាតិសៀមរាប**

អាសយដ្ឋាន ៖ ភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ ៖ ០៦១ ៨០០ ៣៨៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក សេង ឈុន ប្រធានរដ្ឋបាល និង ធនធានមនុស្ស(សៀមរាប)

២- លោក ផន ដា ប្រធានផ្នែកធនធានមនុស្ស(ភ្នំពេញ)

៣- លោក ហេង ចាន់វាសនា ជំនួយការផ្នែកច្បាប់(ភ្នំពេញ)

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជានៃព្រលានយន្តហោះសៀមរាប**

អាសយដ្ឋាន៖ ភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ ៖ ០៨៩ ២៨៨ ២៩៦/០១២ ៩៧៨ ០០៧

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ព្រិត សុអួត មន្ត្រីច្បាប់របស់ ACILS

២- លោក យិន គីមអេង មន្ត្រីសហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា

៣- លោក វ៉ែន វ៉ាវ៉ាន់ ប្រធានសហជីពមូលដ្ឋាន(សៀមរាប)

៤- លោក ពិន សុជា អនុប្រធានសហជីពមូលដ្ឋាន(សៀមរាប)

៥- លោក ស សុហ៊ីម លេខាសហជីពមូលដ្ឋាន(សៀមរាប)

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីសហជីពទាមទារអោយនិយោជករក្សានូវការទូទាត់សងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ទៅថ្ងៃបន្ទាប់ ប្រសិនជាថ្ងៃសម្រាកនោះ ប៉ះចំថ្ងៃប្រជុំជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងការដោះស្រាយវិវាទរបស់ថ្នាក់ដឹកនាំសហជីព ឬក៏មានការអញ្ជើញពីតំណាងរាជរដ្ឋាភិបាលចូលរួមសិក្ខាសិលា ឬ ប្រជុំផ្សេងៗ ដូចធ្លាប់អនុវត្តកន្លងមកដដែលវិញ និងស្នើសុំអោយរាល់ការប្រជុំនៅក្នុងក្រុមហ៊ុន សូមអោយធ្វើកំណត់ហេតុនៅក្នុងថ្ងៃប្រជុំនោះ ហើយចុះហត្ថលេខាទាំងអស់គ្នា។ ភាគីនិយោជកបដិសេធលើចំណុចទាមទាររបស់សហជីព និងស្នើសុំអោយភាគីខាងសហជីពជួបប្រជុំជាមួយខាងក្រុមហ៊ុនសិន នូវរាល់បណ្តឹង មុននឹងប្តឹងមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។

២- ភាគីសហជីពទាមទារអោយនិយោជកអនុវត្តកិច្ចព្រមព្រៀង ស្តីពីកិច្ចព្រមព្រៀងបញ្ចប់វិវាទ និងកូដកម្ម ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ ត្រង់ខ្លឹមសារប្រការ៥ និងស្មារតីនៃកិច្ចប្រជុំថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ចំណុច២។ ភាគីនិយោជកបដិសេធលើចំណុចទាមទាររបស់សហជីព និងស្នើសុំអោយភាគីខាងសហជីពជួបប្រជុំជាមួយខាងក្រុមហ៊ុនសិន នូវរាល់បណ្តឹង មុននឹងប្តឹងមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមក្រុមហ៊ុន អាកាសយានដ្ឋានអន្តរជាតិសៀមរាប លេខ ០៨៤ ម.ក.ប ចុះថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្រ្ទទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជានៃព្រលានយន្តហោះសៀមរាប ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ២ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ បានចាត់មន្ត្រីជំនាញ ឱ្យដោះស្រាយវិវាទការងារនេះតាមនីតិវិធីច្បាប់ និងធ្វើការផ្សះផ្សានៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩ ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អាកាសយានដ្ឋានអន្តរជាតិសៀមរាប លេខ ០៨៤ ម.ក.ប ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៩។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ២ ចំណុចនេះ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ នៅថ្ងៃសវនាការ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុ និងបានផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត នៅក្នុងសវនាការ។ ភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទទី២ ចេញពីសំណុំរឿងនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាតែចំណុចមិនសះជាដែលនៅសល់ចំនួន១ ចំណុចប៉ុណ្ណោះ គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១៩ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់លោក យ៉ាននីក [illegible] នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា (ក្រុមហ៊ុន CAMS) ផ្ទេរសិទ្ធិ

ជូន លោក សេង ឈុន, លោក ផន ដា និងលោក ហេង ចាន់វាសនា ដើម្បីចូលរួមដំណើរការនីតិវិធីដោះស្រាយវិវាទការងារ ទាក់ទងនឹងពាក្យបណ្តឹងរបស់សហជីព។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជ្មែន សឺវីស លេខ MOC-២២១០៩២០៥ ពណ.ចបព ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៥។

៣- កិច្ចព្រមព្រៀងបញ្ចប់វិវាទ និងកូដកម្ម ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា និងសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប។

៤- លិខិតលេខ ១០៨១ សជណ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីលទ្ធផលកិច្ចប្រជុំពិភាក្សាសម្របសម្រួលផ្សះផ្សាវិវាទការងាររួមនៅព្រលានយន្តហោះអន្តរជាតិសៀមរាប។

៥- កំណត់ហេតុនៃកិច្ចប្រជុំ ស្តីពីកិច្ចប្រជុំរវាងថ្នាក់ដឹកនាំក្រុមហ៊ុន និងថ្នាក់ដឹកនាំសហជីព ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៥។

៦- លិខិតចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើដាក់ឯកសារ និងទឡ្ហីករណ៍បន្ថែមលើសំណុំរឿងលេខ ០៩២/១៩ របស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាល។

៧- ឯកសារអនុសញ្ញារួម ២០១៤-២០១៦។

៨- ពាក្យសុំច្បាប់ឈប់សម្រាក។

៩- លិខិតអញ្ជើញលេខ ១១៧ មកប ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប អញ្ជើញលោក-លោកស្រីប្រធានសហជីពកម្មករ ឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប ដើម្បីផ្សះផ្សាវិវាទការងារ។

១០- លិខិតអញ្ជើញលេខ ១៤៦ មកប ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប អញ្ជើញលោក-លោកស្រីប្រធានសហជីពកម្មករ ឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប ដើម្បីផ្សះផ្សាវិវាទការងារ។

១១- លិខិតរបស់ក្រុមហ៊ុន ជូនចំពោះលោក រ៉ែ រ៉ាវ៉ាន់ ប្រធានសហជីពកម្មករឧស្សាហកម្ម ទេសចរណ៍កម្ពុជាព្រលានយន្តហោះសៀមរាប, លោក សុខ សុវណ្ណ ប្រធានសហជីពកម្មករកម្ពុជា ក្រុមហ៊ុន CAMBODIA AIRPORT សៀមរាប, លោក សូ សៅហឿន ប្រធានសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងលោក យិន សារិន ប្រធានសហជីព និយោជិតនៃក្រុមហ៊ុនព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ ស្តីពីអញ្ជើញចូលរួមប្រជុំស្តីពីអនុសញ្ញារួម និងតម្រូវការពាក់ព័ន្ធមុនការចចារ ចុះថ្ងៃអង្គារ ១៣រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

១២- លិខិតចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំជំទាស់ឯកសារ និងហេតុផលរបស់ភាគីសហជីពលើសំណុំរឿងលេខ ០៩២/១៩ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

១៣- លិខិតលេខ ០០១៦/១៩/វិវាទ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ របស់សហជីពកម្មករ ឧស្សាហកម្មទេសចរណ៍កម្ពុជានៃព្រលានយន្តហោះសៀមរាប គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណានៃក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិកម្ពុជាខេត្តសៀមរាប (CAMBODIA AIRPORT/VINCI/SCA/CAMS)។

១៤- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចាត់តាំងលេខ ០៥០/១៩ ACILS របស់មជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីចាត់តាំងឈ្មោះ ព្រិត សុអួត មន្ត្រីច្បាប់ ចូលរួមដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

២- លិខិតលេខ លេខ ០០២ ម.ក.ប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប ជាអង្គការវិជ្ជាជីវៈមួយបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជា-ជីវៈ ខេត្តសៀមរាប និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប លេខ ០២២/១៩ ក.ប/វ.ប.វ.ក ចុះថ្ងៃសុក្រ ១៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩។

៤- កិច្ចព្រមព្រៀងបញ្ចប់វិវាទ និងកូដកម្ម ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះកម្ពុជា និងសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប។

៥- ប្រកាសស្តីពីប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល លេខ ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩។

៦- ឯកសារអនុសញ្ញារួម ២០១៤-២០១៦។

៧- លិខិតលេខ ០៣១/១៩.សកឧទកពស. ចុះថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប គោរពជូន ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តសៀមរាប ស្តីពីស្នើសុំជួយអន្តរាគមន៍ដោះស្រាយបញ្ហានិយោជកក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិ ខេត្តសៀមរាប CAMBODIA AIRPORT/VINCI/SCA/CAMS មិនព្រមគោរពកិច្ចព្រមព្រៀងបញ្ចប់វិវាទការងាររួម ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤។

៨- លិខិតលេខ ០០១៤ ស.ជ.ក ចុះថ្ងៃចន្ទ ១២រោច ខែផល្គុន ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់សហព័ន្ធសហជីពកម្មករ វិស័យដឹកជញ្ជូនកម្ពុជា (CTWF) គោរពជូន

THE ARBITRATION COUNCIL

លោកអគ្គនាយកក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិកម្ពុជា (SCA/CAMS) ស្តីពីស្នើដោះស្រាយបញ្ចប់វិវាទករណីលោក សុខ សារឿន, លោក និន កុសល, លោក នូ គឿន និងលោក កោ ចាន់រិទ្ធិ។

៩- លិខិតលេខ ០០១៥ ស.ជ.ក ចុះថ្ងៃចន្ទ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សហព័ន្ធសហជីពកម្មករ វិស័យដឹកជញ្ជូនកម្ពុជា (CTWF) គោរពជូន លោកអគ្គនាយកក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិកម្ពុជា (SCA/CAMS) ស្តីពីស្នើដោះស្រាយបញ្ចប់វិវាទករណីលោក សុខ សារឿន, លោក និន កុសល, លោក នូ គឿន និងលោក កោ ចាន់រិទ្ធិ (លើកទី២)។

១០- វិធានផ្ទៃក្នុងសំរាប់ការចរចាអនុសញ្ញារួមថ្មី រវាងក្រុមហ៊ុន បំរើសេវាកម្មគ្រប់គ្រងព្រលានយន្តហោះ កម្ពុជា (CAMS) និងសហជីពកម្មករនិយោជិតឯករាជ្យព្រលានយន្តហោះអន្តរជាតិភ្នំពេញ (IAWIU) និងសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប (SACTIW-U)។

១១- លិខិតលេខ ០០១៦/១៩/វិវាទ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ របស់សហជីពកម្មករ ឧស្សាហកម្មទេសចរណ៍កម្ពុជានៃព្រលានយន្តហោះសៀមរាប គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណានៃក្រុមហ៊ុនអាកាសយានដ្ឋានអន្តរជាតិកម្ពុជាខេត្តសៀមរាប (CAMBODIA AIRPORT/VINCI/SCA/CAMS)។

១២- ពាក្យសុំច្បាប់ឈប់សម្រាក។

១៣- លិខិតជំទាស់របស់ថ្នាក់ដឹកនាំ និងសមាជិកសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប លេខ ០០១៧/១៩/វិវាទ ចុះថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីបដិសេធឯកសារភស្តុតាង និងទឡ្ហីករណ៍របស់ក្រុមហ៊ុន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។

១៤- ឯកសារជាភាសាបរទេស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមក្រុមហ៊ុន អាកាសយានដ្ឋានអន្តរជាតិ ខេត្តសៀមរាប លេខ ០៨៤ ម.ក.ប ចុះថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៦៥៣ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូឌា អ៊ែរផត មែនីជម៉្មិន សឺវីស្ស ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩។

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុត សហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប លេខ ០២២/១៩ ក.ប/វ.ប.វ.ក ចុះថ្ងៃសុក្រ ១៣កើត ខែបុស្ស ឆ្នាំចសំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥២៥ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥២៦ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖

អាកាសយានដ្ឋានអន្តរជាតិសៀមរាប មានសកម្មភាពចម្បងផ្នែកសេវាកម្មព្រលានយន្តហោះ និងជើងហោះហើរយន្តហោះ។ អាកាសយន្តដ្ឋានអន្តរជាតិសៀមរាបនេះ មានជួលកម្មករនិយោជិតសរុប ចំនួន ៥៦៣ នាក់ *(យោងតាមរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងសហជីពកម្មករឧស្សាហកម្មទេសចរណ៍កម្ពុជា នៃព្រលានយន្តហោះសៀមរាប)*។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិត ទាមទារឱ្យនិយោជករក្សានូវការសងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ ទៅថ្ងៃបន្ទាប់ បើថ្ងៃឈប់សម្រាកនោះប៉ះចំថ្ងៃប្រជុំជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងការដោះស្រាយវិវាទរបស់ថ្នាក់ដឹកនាំសហជីព ឬក៏មានការអញ្ជើញពីតំណាងរដ្ឋាភិបាល ដើម្បីចូលរួមសិក្ខាសាលា ឬប្រជុំផ្សេងៗ ដូចធ្លាប់អនុវត្តកន្លងមក**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ទៅថ្ងៃបន្ទាប់សម្រាប់ថ្នាក់ដឹកនាំសហជីពត្រូវបានអញ្ជើញឱ្យមកចូលរួមដោះស្រាយវិវាទការងារនៅមន្ទីរការងារ និងនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលជូនពួកគាត់។
- ភាគីទាំងពីរទទួលស្គាល់ថា ការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកអនុញ្ញាតឱ្យកម្មករនិយោជិតមានថ្ងៃឈប់សម្រាកមួយថ្ងៃក្នុងមួយសប្ដាហ៍ ប៉ុន្តែ ការឈប់សម្រាកនេះ មិនមែននៅថ្ងៃចុងសប្ដាហ៍នោះទេ គឺកម្មករនិយោជិតផ្លាស់វេនគ្នាឈប់សម្រាក។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា៖
    - ចាប់ពីឆ្នាំ២០១៣ និយោជកបានសងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ទៅថ្ងៃបន្ទាប់ ជូនថ្នាក់ដឹកនាំសហជីព ដែលបានចូលរួមកិច្ចប្រជុំ ឬសិក្ខាសាលាផ្សេងៗ ចំថ្ងៃឈប់សម្រាករបស់ពួកគាត់។
    - នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ និយោជកប្រកាសបញ្ឈប់ការសងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍សម្រាប់ការចូលរួមដោះស្រាយវិវាទការងាររបស់កម្មករនិយោជិត និងថ្នាក់ដឹកនាំសហជីព។
    - និយោជកបញ្ឈប់ការសងថ្ងៃឈប់សម្រាកនេះ ធ្វើឱ្យកម្មករនិយោជិតបាត់បង់អត្ថប្រយោជន៍ និងមិនមានមូលហេតុសមរម្យនោះទេ។
    - សហជីពចូលរួមដោះស្រាយវិវាទ និងចូលរួមប្រជុំផ្សេងៗ គឺសម្រាប់ផលប្រយោជន៍រួមរបស់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន។

THE ARBITRATION COUNCIL

- ○ នៅក្នុងវិធានផ្ទៃក្នុងសម្រាប់ចរចាអនុសញ្ញារួមថ្មី ក៏មានការផ្តល់សិទ្ធិជូនសហជីពផងដែរ។
- ភាគីនិយោជកបញ្ជាក់ថា និយោជកមិនអាចអនុវត្តតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា៖
  - ○ និយោជកមិនមានគោលការណ៍រួម ឬគោលការណ៍ដោយស្វ័យប្រវត្តិណា ក្នុងការទូទាត់សងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជូនថ្នាក់ដឹកនាំសហជីពជានោះទេ។ ការសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍នេះ មានតែករណីខ្លះប៉ុណ្ណោះ ដូចជា ករណីដែលនិយោជកអញ្ជើញពួកគាត់មកចូលរួមប្រជុំផ្សេងៗ។ ចំពោះករណី លោក ស សុហ៊ីម និយោជកបានទូទាត់សងការឈប់សម្រាកប្រចាំសប្តាហ៍ជូនគាត់ដោយសារនិយោជកអញ្ជើញគាត់ចូលរួមកិច្ចប្រជុំ។
  - ○ លើសពីនេះទៀត និយោជកបានអនុញ្ញាតឱ្យកម្មករនិយោជិតដែលមកចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឈប់សម្រាកចំនួន ៣ថ្ងៃ ដោយមានប្រាក់ឈ្នួលរួចហើយ។
  - ○ អនុសញ្ញារួមឆ្នាំ២០១៤-២០១៦ គឺផុតរលត់ហើយ ដូច្នេះ មិនអាចយកមកអនុវត្តបានទៀតនោះទេ។
  - ○ វិធានផ្ទៃក្នុងសម្រាប់ចរចាអនុសញ្ញារួមថ្មី ផ្តោតសំខាន់តែលើអនុសញ្ញារួមតែប៉ុណ្ណោះ។ ម្យ៉ាងទៀត នៅក្នុងប្រការ៤ ចំណុច ៤.៤ បានកំណត់ថា និយោជកនឹងមិនកាត់ប្រាក់ឈ្នួល ឬឱ្យច្បាប់ឈប់សម្រាកដោយមានប្រាក់ឈ្នួល និងអត្ថប្រយោជន៍នានាទៅតាមចំនួនថ្ងៃនៃកិច្ចប្រជុំនោះ ប៉ុន្តែ មិនមានកំណត់ថាប្រជុំចំថ្ងៃឈប់សម្រាក លើកទៅថ្ងៃបន្ទាប់នោះទេ។
- យោងតាមឯកសាររបស់ភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា៖
  - ○ អនុសញ្ញារួម ឆ្នាំ២០១៤-២០១៦ បានផុតសុពលភាពហើយ។
  - ○ វិធានផ្ទៃក្នុងសំរាប់ការចរចារអនុសញ្ញារួមថ្មី មានវិសាលភាពអនុវត្តសម្រាប់ការចរចាអនុសញ្ញាអនុសញ្ញារួម តែប៉ុណ្ណោះ។
  - ○ កាលវិភាគការងារប្រចាំខែ (Maonthly Roster) សម្រាប់ខែតុលា ឆ្នាំ២០១៩ ចំពោះកម្មករនិយោជិត វ៉ន រ៉ាវ៉ន ការឈប់សម្រាកប្រចាំសប្តាហ៍ត្រូវថ្ងៃទី១០ ខែតុលា ឆ្នា២០១៩ និយោជកមិនទូទាត់សងជូនគាត់។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទូទាត់សងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ទៅថ្ងៃបន្ទាប់ នៅពេលថ្នាក់ដឹកនាំសហជីពចូលរួមដោះស្រាយវិវាទការងារនៅមន្ទីរការងារ និងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ជូនពួកគាត់**

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនទាន់មានថ្នាក់ដឹកនាំសហជីពណាម្នាក់ដែលត្រូវបានអញ្ជើញឱ្យមកចូលរួមដោះស្រាយវិវាទនៅមន្ទីរការងារ ចំថ្ងៃដែលពួកគាត់មានសិទ្ធិឈប់សម្រាកប្រចាំសប្តាហ៍នៅឡើយទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាការទាមទារនេះទេ។ ចំពោះការទាមទារសម្រាប់ករណីថ្នាក់ដឹកនាំសហជីពដែលត្រូវបានអញ្ជើញឱ្យមកចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា គឺមានករណីលោក វ៉ន រ៉ាវ៉ន់ ជាថ្នាក់ដឹកនាំសហជីព

ARBITRATION COUNCIL

ដោយការឈប់សម្រាករបស់គាត់ត្រូវថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាចំណុចវិវាទនេះសម្រាប់តែករណីលោក រ៉ែន រ៉ាវ៉ាន់ ប៉ុណ្ណោះ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចក្នុងការសងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ ជូនលោក រ៉ែន រ៉ាវ៉ាន ដោយសារគាត់ចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលចំថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍របស់គាត់ ដែរឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានចែងថា ៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬបិទទ្វារសហគ្រាស (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្ដីពីការងារ) ...។ ភាគីទាំងនេះ ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម"*។

ប្រការ ១៤ នៃប្រកាសលេខ ០៩៩ សកបយ. ខាងលើ បានចែងថា ៖ *"ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ត្រូវគេតំរូវឱ្យចូលរួមក្នុងសវនាការជំនុំជំរះរបស់ក្រុមអាជ្ញាកណ្ដាលក្នុងពេលម៉ោងធ្វើការនិយោជករបស់កម្មករនិយោជិត នោះត្រូវតែអនុញ្ញាតឱ្យកម្មករនិយោជិតនោះចូលរួមដោយមិនឱ្យទទួលផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិការងារទាំងឡាយដែលកម្មករនិយោជិតនោះមានឡើយ"*។

យោងតាមប្រការ ២០ និងប្រការ ១៤ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកមានកាតព្វកិច្ចក្នុងការអនុញ្ញាតឱ្យកម្មករនិយោជិតដែលបានទទួលលិខិតអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីទៅចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងអំឡុងពេលនៃម៉ោងធ្វើការរបស់ពួកគាត់ ដោយនិយោជកមិនត្រូវកាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងទៀតរបស់ពួកគាត់ឡើយ។ *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ០៩១/១៥-ដាប់ប៊ិលយូ អ៊ែនដ៍ ឌី (កម្ពុជា) ហេតុផលនៃចំណុចវិវាទទី៧, លេខ ០០៥/១៦-វ៉ាយអិលជី អ៊ិនដើណេសិនណល ហេតុផលនៃចំណុចវិវាទទី៤, លេខ* ០៩៨/១៦-គ្រីស្ដាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត *ហេតុផលនៃចំណុចវិវាទទី៤, លេខ ០០៣/១៧-ហ៊ីង ជីង ហេតុផលនៃចំណុចវិវាទទី៤ និងលេខ ០១២/១៧-ហ្វ៊ីស ហ្គាវ៉េន្ត អ៊ីកែវីល (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៥)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងសំណុំរឿងមុនៗដែរ។

លើសពីនេះទៀត បើទោះបីជាប្រការ ១៤ នៃប្រកាស ០៩៩ ខាងលើ មិនបានបញ្ជាក់ពីការចូលរួមសវនាការនៅថ្ងៃឈប់សម្រាករបស់កម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា គោលបំណងនៃប្រការនេះ គឺចង់លើកទឹកចិត្តនិងរក្សាផលប្រយោជន៍កម្មករនិយោជិតដែលមកចូលរួមសវនាការ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ក្នុងករណីដែលកម្មករនិយោជិតមកចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចំថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍របស់ពួកគាត់ កម្មករនិយោជិតក៏ត្រូវទទួលបាននូវការរក្សាសិទ្ធិការងាររបស់ពួកគាត់ផងដែរ។

សម្រាប់ករណីលោក រ៉ែន រ៉ាវ៉ាន ដែលជាថ្នាក់ដឹកនាំសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្ដាលកត់សម្គាល់ឃើញថា និយោជកបានអនុញ្ញាតឱ្យគាត់ឈប់សម្រាកពីការងាររយៈពេល ៣ថ្ងៃ សម្រាប់ការចូលរួមសវនាការ នៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលរយៈពេលកន្លះថ្ងៃ ឬមួយថ្ងៃ ដោយសារគាត់ត្រូវធ្វើដំណើរទៅមក (សៀមរាប-ភ្នំពេញ)។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការផ្ដល់ជូននេះ គឺមានលក្ខណៈល្អប្រសើរជាងច្បាប់ ទោះបីជាយ៉ាង

THE ARBITRATION COUNCIL

ណាក៏ដោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការធ្វើដំណើរនោះនៅតែប៉ះពាល់ដល់សិទ្ធិឈប់សម្រាកប្រចាំសប្តាហ៍របស់លោក រ៉ែន រ៉ាវ៉ាន នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ដោយសារក្រុមហ៊ុននេះ ផ្តល់សេវាកម្មព្រលានយន្តហោះ និងជើងហោះហើរ ដែលតម្រូវឱ្យកម្មករនិយោជិតឈប់សម្រាកប្រចាំសប្តាហ៍នៅថ្ងៃផ្សេងក្រៅពីថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការឈប់សម្រាកប្រចាំសប្តាហ៍ ក៏ជាសិទ្ធិការងារមួយរបស់កម្មករនិយោជិត។ ហេតុនេះ យោងតាមការបកស្រាយខាងលើ និយោជកត្រូវរក្សាសិទ្ធិនៃការឈប់សម្រាកប្រចាំសប្តាហ៍នេះ ដូចគ្នានឹងការរក្សាប្រាក់ឈ្នួលជូនកម្មករនិយោជិតដែលមកចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។ ដូច្នេះ និយោជកមានកាតព្វកិច្ចប្តូរថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍របស់លោក រ៉ែន រ៉ាវ៉ាន ទៅថ្ងៃផ្សេងទៀត។

យ៉ាងណាមិញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការប្តូរថ្ងៃឈប់សម្រាករបស់កម្មករនិយោជិតអាចនឹងមានផលប៉ះពាល់ដល់ដំណើរការរបស់អាកាសយានដ្ឋាន។ ហេតុនេះ ការកំណត់ថ្ងៃថ្មីសម្រាប់ការឈប់សម្រាកប្រចាំសប្តាហ៍នេះ គួរតែផ្អែកតាមការចាត់ចែងរបស់និយោជក និងអាស្រ័យទៅលើភាពចាំបាច់នៃដំណើរការក្រុមហ៊ុន។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ជូនលោក រ៉ែន រ៉ាវ៉ាន់ ដែលចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល (ចំថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩) ទៅថ្ងៃផ្សេង ស្របតាមការចាត់ចែងរបស់និយោជក។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បង្គាប់ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ជូនលោក រ៉ែន រ៉ាវ៉ាន់ សម្រាប់ការចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ទៅថ្ងៃផ្សេង តាមការចាត់ចែងរបស់និយោជក។
- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ជូនថ្នាក់ដឹកនាំសហជីពដែលមកចូលរួមដោះស្រាយវិវាទនៅមន្ទីរការងារ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា-ជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាលដែល**
**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**
ឈ្មោះ ៖ **ម៉ារ សំបូរណា**
ហត្ថលេខា ៖ ----------------------------

ARBITRATION COUNCIL

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ឈាន**

ហត្ថលេខា ៖------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ០៩១/១៩-អាកាសយានដ្ឋានអន្តរជាតិសៀមរាប**

## យោបល់ជំទាស់ទៅលើសេចក្តីសម្រេច
## នៃសំណុំរឿងលេខ ០៩១/១៩-អាកាសយានដ្ឋានអន្តរជាតិសៀមរាប
## ដោយអាជ្ញាកណ្តាល ម៉ារ សំបូរណា ដែលជ្រើសរើសដោយភាគីនិយោជក

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រាពាល់សេចក្តីសម្រេចរបស់ខ្លួនក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣ រូប។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់* ***មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្តីបង្គាប់នោះ"*****។**

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **ម៉ារ សំបូរណា** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេច និងសេចក្តីបង្គាប់លេខ **០៩១/១៩-អាកាសយានដ្ឋានអន្តរជាតិសៀមរាប** ត្រង់**ចំណុចវិវាទទី១** ដែលអាជ្ញាកណ្តាលពីររូបទៀត បង្គាប់ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ជូនកម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ សម្រាប់ការចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ទៅថ្ងៃផ្សេង តាមការចាត់ចែងរបស់និយោជក។

ខ្ញុំអាជ្ញាកណ្តាល ម៉ារ សំបូរណា សូមជំទាស់ទៅនឹងការសម្រេចរបស់លោកអាជ្ញាកណ្តាលទាំង២ នៃសំណុំរឿងនេះ បង្គាប់ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជូនកម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ សម្រាប់ការចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ខណៈពេលដែលកម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ បានទទួលច្បាប់អនុញ្ញាតសម្រាកដោយមានប្រាក់ឈ្នួលចំនួន ៣ ថ្ងៃ រួចទៅហើយពីភាគីនិយោជក គឺសម្រាប់ការធ្វើដំណើរ និងចូលសវនាការនៅក្នុងដំណើរការអាជ្ញាកណ្តាលកន្លះថ្ងៃ នៃថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ នៅភ្នំពេញ។ ក្រុមអាជ្ញាកណ្តាលបានទទួលស្គាល់ក្នុងហេតុផលរបស់ខ្លួនថា ការផ្តល់ជូនរយៈពេល ៣ ថ្ងៃ ខាងលើនេះ ជូនកម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ ចូលរួមសវនាការ គឺមានលក្ខណៈល្អប្រសើរជាងច្បាប់ ប៉ុន្តែបែរជាផ្តល់បន្ថែមចំនួន ១ថ្ងៃ ជូនកម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ ទៀត ជំនួសថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ដែលមិនមានការកំណត់ជាក់លាក់ណាមួយនៅក្នុងបញ្ញត្តិនៃច្បាប់ ឬកិច្ចព្រមព្រៀងណាមួយ រវាងគូភាគីវិវាទឡើយ សម្រាប់ការសងជំនួសថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍នេះ។

ជាការពិតណាស់ថា កម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ មានសិទ្ធិទទួលបានការឈប់សំរាកប្រចាំសប្តាហ៍តាមការកំណត់នៃច្បាប់ ហើយត្រូវចំថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ដែលជាថ្ងៃធ្វើសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ កម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ មានជំរើសក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់ក្នុងការឈប់សំរាក ដោយមិនទៅចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ បាន ដោយអាចស្នើសុំលើកពេលទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬចាត់តាំងថ្នាក់ដឹកនាំសហជីពផ្សេងទៀត ឬអ្នកតំណាងទៅចូលរួមជំនួសខ្លួនឯងបាន។

ក៏ប៉ុន្តែ កម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ បានសម្រេចចិត្តមកចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងនាមថ្នាក់ដឹកនាំសហជីព នៃភាគីកម្មករនិយោជិតនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប។ តាមន័យនេះ គឺមានន័យថា កម្មករនិយោជិត រ៉ែន រ៉ាវ៉ាន់ បានលះបង់សិទ្ធិប្រើប្រាស់ថ្ងៃ១០ ខែតុលា

THE ARBITRATION COUNCIL

ឆ្នាំ២០១៩ ដោយខ្លួនឯង ក្នុងការប្រើប្រាស់ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍របស់ខ្លួន មកចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាមួយថ្នាក់ដឹកនាំសហជីព និងតំណាងកម្មករនិយោជិតផ្សេងៗទៀត។

ការប្តឹងទាមទារឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ សម្រាប់ការមកចូលរួមសវនាការនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ដែលកម្មករនិយោជិត រ៉ន រ៉ាវ៉ាន់ បានបោះបង់សិទ្ធិប្រើប្រាស់ដោយខ្លួនឯង ខណៈពេលដែលមិនមានបញ្ញត្តិ ឬកិច្ចព្រមព្រៀងណាមួយ ចែងអំពីការផ្តល់ថ្ងៃជំនួសថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ គឺជាការទាមទារនូវអត្ថប្រយោជន៍ដែលលើសពីច្បាប់។

ការចេញសេចក្តីបង្គាប់ផ្តល់ប្រយោជន៍លើសពីច្បាប់ គឺជាសេចក្តីបង្គាប់លើវិវាទផលប្រយោជន៍ នឹងក្លាយទៅជាអនុសញ្ញារួមមួយ ដែលភ្ជាប់កាតព្វកិច្ចភាគីទាំងពីរ រយៈពេលមួយ(០១) ឆ្នាំ ក្រោយសេចក្តីបង្គាប់នេះចូលជាធរមាន ប្រសិនជាមិនមានភាគីណាមួយបដិសេធទេនោះ។

ហេតុដូចនេះ ខ្ញុំយល់ថា គួរសម្រេចបដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ជូនកម្មករនិយោជិត រ៉ន រ៉ាវ៉ាន់ សម្រាប់ការចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សា-អាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ទៅថ្ងៃផ្សេង តាមការចាត់ចែងរបស់និយោជក។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩
ហត្ថលេខារបស់អាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**ម៉ារ សំបូរណ៍**